សង់ត្រាល់ CENTRAL

CAMBODIAN TRADE UNIONS FEDERATION

លីកាដូ LICADHO

អង្គការសហគមន៍ទាំងត្នោត
Sahmakum Teang Tnaut - a Cambodian urban NGO

# ជម្រាបជូន

- **ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**
- **ប្រធានសមាគមធនាគារនៅកម្ពុជា**

យើងខ្ញុំបានអាន លិខិតចំហររបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមធនាគារនៅកម្ពុជា ដែលបានផ្សព្វផ្សាយនៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា កាលពីយប់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២០នេះ និងបានជម្រាបជូនមកអង្គការ និងសហជីពយើងខ្ញុំ ទាំង៤ស្ថាប័ន ។

ជាជំហររួមយើងខ្ញុំ សូមបដិសេធសំណើរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមធនាគារនៅកម្ពុជា ក្នុងការកែប្រែទៅលើរបាយការណ៍ទាំង៣ ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងកម្ចីឥណទានខ្នាតតូច នៅកម្ពុជា ។ ព័ត៌មាន និងរឿងរ៉ាវរបស់បុគ្គលនៅក្នុងរបាយការណ៍ដែលបានចុះផ្សាយទាំងនេះ គឺនៅតែមានភាពច្បាស់លាស់ត្រឹមត្រូវដដែលដោយមិនអាចកែប្រែបាន ។ យើងខ្ញុំ នឹងបន្តការពារឯកជនភាពបុគ្គលដែលសម្រេចចិត្តចែករំលែករឿងរ៉ាវរបស់ពួកគាត់ជាមួយក្រុមអ្នកសិក្សាស្រាវជ្រាវយើងខ្ញុំ ក្នុងលក្ខខណ្ឌលាក់បាំងអត្តសញ្ញាណ ។ យើងខ្ញុំ សូមលើកទឹកចិត្ត សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមធនាគារនៅកម្ពុជា ក៏ដូចជាភាគីពាក់ព័ន្ធ ឱ្យអានរបាយការណ៍ទាំងនេះ ឱ្យបានលម្អិត ដើម្បីឈ្វេងយល់កាន់តែច្បាស់អំពី គោលបំណង វិធីសាស្ត្រ និងការរកឃើញផ្សេងៗនៅក្នុងរបាយការណ៍ ។

សិទ្ធិមនុស្សគឺជាសិទ្ធិមានពីកំណើតរបស់មនុស្សគ្រប់រូប ហើយរឿងរ៉ាវរបស់មនុស្សគឺជាមូលដ្ឋានគ្រឹះសំខាន់នៃការស្រាវជ្រាវបែបគុណភាព ។ ការងារមួយក្នុងចំណោមការងារផ្សេងទៀតរបស់យើងខ្ញុំគឺ ដើម្បីជួយបន្លឺសំឡេងរបស់ប្រជាពលរដ្ឋ ដែលកំពុងរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងផ្សព្វផ្សាយរឿងរ៉ាវទាំងនោះឱ្យបានទូលំទូលាយ ក្នុងគោលបំណងដើម្បីឱ្យមានការកែប្រែជាវិជ្ជមាននៅក្នុងសង្គម និងដើម្បីការពារកុំឱ្យកើតមានការរំលោភបំពានផ្សេងៗ ។ យើងខ្ញុំ នឹងបន្តផ្សព្វផ្សាយ និងចែករំលែកទុក្ខកង្វល់របស់ប្រជាពលរដ្ឋ ទោះបីជាការរៀបរាប់ពីបញ្ហាសិទ្ធិមនុស្សទាំងនេះ ពាក់ព័ន្ធគ្នាទៅនឹងវិស័យមីក្រូហិរញ្ញវត្ថុ និងកម្ចីឥណទានខ្នាតតូចក៏ដោយ ។

ជាថ្មីម្តងទៀត យើងខ្ញុំ សូមយកឱកាសនេះ លើកយកសំណើ និងអនុសាសន៍ ដែលក្រុមសង្គមស៊ីវិលបានផ្ញើជូនទៅ អ្នកផ្តល់កម្ចីឥណទានខ្នាតតូចទាំងអស់ ដើម្បីទប់ស្កាត់កុំឱ្យកើតមានការរំលោភសិទ្ធិមនុស្សនៅក្នុងវិស័យនេះ ក្នុងនោះរួមមាន៖

១. សូមកែប្រែបទបញ្ញាផ្ទៃក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីហាមឃាត់ការទាមទារដាក់ប័ណ្ណសម្គាល់កម្មសិទ្ធ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី ធ្វើជាទ្រព្យធានា សម្រាប់កម្ចីឥណទានខ្នាតតូចថ្មីទាំងអស់ ។

២. សូមគណនា និងចេញផ្សាយជាសាធារណៈនូវចំនួនប័ណ្ណសម្គាល់កម្មសិទ្ធ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី ដែលត្រូវបានដាក់តម្កល់ជាទ្រព្យធានា ។

៣. សូមបញ្ឈប់ការដាក់សម្ពាធលើអតិថិជនឱ្យលក់ដី ដើម្បីដោះបំណុល និងជំនួសវិញដោយការដោះស្រាយតាមរយៈការប្រើប្រាស់យន្តការផ្លូវច្បាប់ដែលមានស្រាប់ សម្រាប់អតិថិជនដែលគ្មានលទ្ធភាពសងបំណុល ។

៤. សូមបញ្ឈប់ការយកកម្រៃបង់មុន ដែលនាំឱ្យអត្រាការប្រាក់ពិតលើសពី ពិដានអត្រាការប្រាក់ ១៨ភាគរយក្នុងមួយឆ្នាំ ដែលបានកំណត់ដោយធនាគារជាតិកម្ពុជា កាលពីខែមីនា ឆ្នាំ២០១៧ ។

៥. សូមគាំទ្រ និងសម្របសម្រួលឱ្យមានការស៊ើបអង្កេតដោយឯករាជ្យលើគ្រប់វិស័យ ទៅលើការអនុវត្តនានារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានធនាគារ និងធានាថា ការសម្រាលបន្ទុក និងសំណងត្រូវបានផ្តល់ឱ្យអតិថិជនអ្នកខ្ចីប្រាក់ នៅពេលដែលមានការរកឃើញកំហុស ។

៦. សូមផ្តល់ការពន្យាពេលសងបំណុលមីក្រូហិរញ្ញវត្ថុ និងការប្រាក់ យ៉ាងតិចបំផុត៣ខែ ដោយផ្តល់អាទិភាពដល់ក្រុមអ្នកខ្ចីប្រាក់ដែលងាយរងគ្រោះដូចជា គ្រួសារ និងសហគមន៍ក្រីក្រ កម្មករនិយោជិតគ្រប់វិស័យដែលត្រូវបានបាត់បង់ការងារ និងត្រូវបានព្យួរការងារ ជាពិសេសអ្នកដែលត្រូវបានសម្គាល់ដោយប័ណ្ណក្រីក្រ ដែលជាអ្នករងគ្រោះខ្លាំងជាងគេដោយសារវិបត្តិសេដ្ឋកិច្ចកើតចេញពីការរីករាលដាលនៃជំងឺកូវីដ១៩ ៕

ដោយក្តីគោរពរាប់អានអំពីយើងខ្ញុំ!

ថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០

**មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងការពារសិទ្ធិមនុស្ស**
**តំណាង**
**មឿន_តុលា**

**សម្ព័ន្ធសហជីពកម្ពុជា**
**តំណាង**

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**
**តំណាង**
**អំ_សំអាត**

**អង្គការសមាគមធាងត្នោត**
**តំណាង**